-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សំរេច

**ប្រការ១:** ត្រូវបានបញ្ចូលសមាសភាពចំនួនពីររូបថ្មីបន្ថែមទៀត ជាសមាជិកនៃគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-វៀតណាម គឺ :

១-លោកឧត្តមសេនីយ៍ត្រី **ថោង លីម** អនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលព្រំដែន ជាសមាជិក

២-លោកវរៈសេនីយ៍ឯក **ខួន សុខណ្ណា** អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន ជាសមាជិក

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងសេចក្ដីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចក្នុងប្រការ៣

-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៥ សសរ

## សេចក្តីសំរេច

## ស្តីពីការបន្ថែមសមាសភាពគណៈកម្មាធិការចំរុះកិច្ចការព្រំដែន

## កម្ពុជា-ឡាវ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ១៨ អនក្រ-បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្មកិច្ចការព្រំដែន ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ១៩ អនក្រ-បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែន ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសំរេចលេខ១៨ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ឡាវ

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សំរេច

**ប្រការ១:** ត្រូវបានបញ្ចូលសមាសភាពចំនួនពីររូបថ្មីបន្ថែមទៀត ជាសមាជិកនៃគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-ឡាវ គឺ :

១-លោកឧត្តមសេនីយ៍ត្រី **ថោង លឹម** អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ជាសមាជិក

២-លោកវរៈសេនីយ៍ឯក **ខួន សុចណ្ណា** អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន ជាសមាជិក

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ឡាវ និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងប្រការ៣

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៧...សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ក្នុងការរៀបចំឯកសារបទដ្ឋានគតិយុត្តិ និងប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទកោះកេរ្តិ៍ និងបឹងមាលា សំរាប់បំរើសំណូមពរវិនិយោគ របស់ ក្រុមហ៊ុន KHAM SOMETH CO., LTD

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ /នស /៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ .ក "គ.វ.ក" នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០១
- តាមសំណើរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សំរេច

**ប្រការ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំរាល់ឯកសារបទដ្ឋានគតិយុត្តិ និងប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទកោះកេរ្តិ៍ និងបឹងមាលា សំរាប់បំរើសំណូមពរវិនិយោគរបស់ក្រុមហ៊ុន KHAM SOMETH CO., LTD. ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឌី យ៉ាវ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម **ជុច ភឿន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម **រស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម **រ៉ែន្ទ សណ្ដាប់** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម **អ៊ិត ណូឌី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | ឯកឧត្តម **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- | ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១- | ឯកឧត្តម **ដោក ណារិន** | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ១២- | ឯកឧត្តម **ព្រាប តាន់** | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៣- | ឯកឧត្តម **រស់ បូរ៉ាត់** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៤- | លោក **ស៊ុយ សាន** | អភិបាលរងទី២ ខេត្តសៀមរាប | សមាជិក |
| ១៥- | លោក **បុទ ម៉ុនឃួន** | ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការដូចមានចែងក្នុងប្រការ១ខាងលើ មានភារកិច្ចដូចខាងក្រោម :

- រៀបចំបែបបទ ឯកសារគតិយុត្តិ-កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំង២កន្លែង"តំបន់ប្រាសាទកោះកេរ្តិ៍-តំបន់ប្រាសាទបឹងមាលា"អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្ដីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមជំហាននីមួយៗ
- លើកសំណើ សុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣** : គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេច នេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *កាលប្បវត្តិ-ឯកសារ*

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០២ ស.អ.ន

**សេចក្ដីអំពាវនាវ**

**របស់រាជរដ្ឋាភិបាលកម្ពុជា**

ថ្ងៃអាទិត្យ ទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ជាទិវាប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ប្រារព្ធការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ជាលើកដំបូង ដើម្បីអនុវត្តលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងអនុវត្តនយោបាយវិមជ្ឈការ ដូចបានកំណត់ក្នុងច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

អនុលោមតាមសេចក្ដីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ ស.អ.ន ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២ និងក្នុងគោលបំណងពង្រឹងស្ថិរភាព សន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងរបៀបរៀបរយ ជៀសវាងការប្រើអំពើហិង្សាផ្សេងៗដោយថាហេតុនោះ រាជរដ្ឋាភិបាល សូមអំពាវនាវដល់ប្រជាពលរដ្ឋជាជនរួមជាតិទាំងអស់ សូមអញ្ជើញទៅធ្វើការបោះឆ្នោត ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ របស់ខ្លួនអោយបានគ្រប់ៗគ្នា និងសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ សូមកុំពិសារស្រា ឬ ភេសជ្ជៈស្រវឹងនៅក្នុងថ្ងៃបោះឆ្នោត នាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះ ។

រាជរដ្ឋាភិបាលសង្ឃឹមថា ជនរួមជាតិទាំងអស់នឹងចូលរួមចំណែកអនុវត្តតាមសេចក្ដីអំពាវនាវនេះ ដោយក្ដីសោមនស្សរីករាយ និងស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ARal

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាល**

**លេខ: ០៤.ប្រក**

## ប្រកាស

## ស្តីពីការជ្រើសរើសមន្ត្រីរាជការ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញលិខិតលេខ ៤៣៤មស.ក្រខ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

**ប្រការ ១** : ជ្រើសរើសអ្នកស្រី **អ៊ាន អមរា** អោយចូលបំរើការងារនៅអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ដោយត្រូវធ្វើកម្មសិក្សារយៈពេល ១២ខែ គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២ តទៅ ។

**ប្រការ ២** : លោកប្រធាននាយកដ្ឋានរដ្ឋបាល - បុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី**

សុខ.អាន

**កន្លែងទទួល**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ២
- ឯកសារ - កាលប្បវត្តិ

2002

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០១៧ MoC / M 2002

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពី

## ការដាក់ឱ្យដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅកាន់ប្រទេសកាណាដា សំរាប់ឆ្នាំ ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងអនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលកាណាដា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការនាំចេញពីប្រទេសកម្ពុជា នូវផលិតផលវាយនភ័ណ្ឌសំរាប់នាំចូលទៅកាន់ប្រទេសកាណាដា ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៥
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ( GSP Department ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០២ ត្រូវបានអញ្ជើញឱ្យចូលរួមដេញថ្លៃ តាមប្រភេទផ្សេងៗនៃកូតា ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

**ប្រការ ២ :** រោងចក្រនីមួយៗ ត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកជាអតិបរមា តែ២០% នៃកូតា ដែលដាក់ឱ្យដេញថ្លៃ តាមប្រភេទនីមួយៗ ដូចខាងក្រោម :

| Cat | Products Coverage | Tender Quantity (PCS) | Others |
|---|---|---|---|
| 5 | Trousers, Coveralls & Shorts<br>( All fibres Including Silk>70%&Vegatable >85% )<br>= Trousers, MB & WG | 150,363 | |
| 8 | ATHLTC,K/C, Blouses, Shirts/T/Sweat, Etc.<br>-T.Shirts<br>-Sweatshirts<br>-Athltc Swear | 150,363 | |
| 9 | Underwear<br>-Men & Boys<br>-Women & Girls<br>-Children | 375,907 | |
| 10 | Sleepwear & Bathrobes<br>-Pyjamas , MBWG<br>-Bathrobes , MBWG<br>-Pyjamas & Bathrobese | 225,544 | |
| 11 | Jarseys, Pullover, Cardigans & Sweaters<br>- Men & Boys<br>-Women & Girls<br>-Children | 150,363 | |
| | **Total** | **1,052,540** | |

**ប្រការ ៣ :** ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានការបញ្ជាក់ពីធនាគារ "Certified Check " ដែលមានតម្លៃស្មើនឹង ១០% នៃតម្លៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ជូនគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមា មិនគ្រប់ចំនួន ១០% នៃតម្លៃសរុបនឹងត្រូវចាត់ទុកពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។

**ប្រការ៤ :** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម **Category** នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុបត្រូវបានបែងចែកអស់ ។

**ប្រការ ៥** : **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ ៦** : តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវកំរិតយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ 0,010 មួយសេនដុល្លារអាមេរិក លើថ្លៃឯកត្តា ។

| Category | Minimum Bid |
|---|---|
| 5 | US$ 0,1 |
| 8 | US$ 0,1 |
| 9 | US$ 0,05 |
| 10 | US$ 0,05 |
| 11 | US$ 0,05 |

**ប្រការ ៧** : ពាក្យសុំដេញថ្លៃ ត្រូវដាក់ជូនគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង អាគារលេខ ២០អា មហាវិថីព្រះនរោត្តម ( នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ) ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ដោយភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ ចំនួន ១០% នៃតម្លៃដេញថ្លៃសរុបដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨** : កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០២ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម អាគារ 20 A ជាន់ទី ២ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ។

**ប្រការ ៩** : កាលបរិច្ឆេទឈប់ទទួលពាក្យសុំដេញថ្លៃ ត្រូវកំណត់ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ វេលាម៉ោង ១៧:០០ នាទី ល្ងាច ។

**ប្រការ ១០** : លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០២ ។

**ប្រការ ១១** : អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចទទួលយកកូតារបស់ខ្លួន ទៅប្រើប្រាស់បាន ក្នុងរយៈពេល ០១ ថ្ងៃ បន្ទាប់ពីបានទូទាត់តម្លៃដេញថ្លៃ ដែលនៅសេសសល់ រួចហើយ ។

**ប្រការ ១២** : អ្នកចូលរួមដេញថ្លៃ ដែលទទួលបានជោគជ័យ ហើយខកខានមិនបាន ទទួលយកបរិមាណកូតា

2002

របស់ខ្លួន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយ បរិមាណកូតាដែលមិនបានទទួលយកនោះ ត្រូវបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធក្នុងការមិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតាលើកក្រោយៗ ទៀតឡើយ ។

<u>ប្រការ</u> ១៣ : អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវផ្តល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួន ។

<u>ប្រការ</u> ១៤ : កូតាដែលទទួលបានតាមរយៈការដេញថ្លៃនេះ នឹងត្រូវបានប្រើប្រាស់សំរាប់តែឆ្នាំសារពើពន្ធ ២០០២ ប៉ុណ្ណោះ យោងតាមអនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលកាណាដា និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងទៅនឹងការនាំចេញពីប្រទេសកម្ពុជា នូវ ផលិតផលវាយនភ័ណ្ឌសំរាប់នាំចូលទៅកាន់ ប្រទេសកាណាដា ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៥ ។

<u>ប្រការ</u> ១៥ : សេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ នៅក្នុងការអនុវត្តការដេញថ្លៃ គឺជាការសំរេចចុងក្រោយ ។

<u>ប្រការ</u> ១៦ : នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, សមាជិកគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ផលិតករសំលៀកបំពាក់ត្រូវអនុវត្តនីប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម-ប្រសិទ្ធ

<u>**ចម្លងជូន**</u> :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា
-រាជកិច្ច ✓
-ទូរទស្សន៍ជាតិ - វិទ្យុជាតិ និងកាសែតជាតិ " ដើម្បីផ្សព្វផ្សាយ "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No.០៧៧ MoC / M 2002

ភ្នំពេញ,ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់ប្រទេសកាណាដា ក្នុងឆ្នាំ ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមអនុស្សរណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលកាណាដា និង រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការនាំចេញពីប្រទេសកម្ពុជា នូវផលិតផលវាយនភ័ណ្ឌសំរាប់នាំចូលទៅកាន់ប្រទេសកាណាដា ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ០១២ MoC/M2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់ប្រទេសកាណាដា សំរាប់ឆ្នាំ ២០០២ ។
- យោងតាមការចាំបាច់នៃការងារ ។

## សំរេច

**ប្រការ ១** : ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយ ៗ សំរាប់ការនាំចេញទៅកាន់ប្រទេសកាណាដាក្នុងឆ្នាំ ២០០២ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០២ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបាន មុនថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិ ក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋាន កាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករ សំលៀកបំពាក់ និង សមាជិកគណៈកម្មការ គ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចំលងជូន</u> :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
  " ដើម្បីជ្រាបជាពត៌មាន "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

12:52 PM, 1/21/02

**MINISTRY OF COMMERCE**

**TENDER of QUOTA**

**TENDER of QUOTA**
**January 21,2002**

| ID | COMPANY NAME | 5 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **150,363** | **$0.10** | | | |
| 1 | SHARP CASUAL CO.,LTD. | 20,000 | $0.50 | $10,000.00 | $1,000.00 | $9,000.00 |
| 2 | TAI YANG ENTERPRISE CO.,LTD. | 30,000 | $0.50 | $15,000.00 | $1,500.00 | $13,500.00 |
| 3 | M.G GARMENT MANUFACTURING CO.,LTD. | 30,000 | $0.30 | $9,000.00 | $900.00 | $8,100.00 |
| 4 | ROO HSING GARMENT CO.,LTD. | 6,150 | $0.30 | $1,845.00 | $184.50 | $1,660.50 |
| 5 | TACK FAT GARMENT (CAMBODIA) LTD. | 11,240 | $0.30 | $3,372.00 | $337.20 | $3,034.80 |
| 6 | TRINNUGGAL KOMARA GA. INDUSTRY CO.,LTD. | 1,100 | $0.30 | $330.00 | $33.00 | $297.00 |
| 7 | ZHENG YONG GARMENT FACTORY Co.,LTD. | 30,000 | $0.30 | $9,000.00 | $900.00 | $8,100.00 |
| 8 | CAMBODIA SPORTSWEAR MFG LTD. | 1,645 | $0.25 | $411.25 | $41.13 | $370.13 |
| 9 | CUNG SING ( CAMBODIA ) GARMENT FTY, LTD. | 494 | $0.25 | $123.50 | $12.35 | $111.15 |
| 10 | DOUBLE WIN INTERNATIONAL CORP | 9,867 | $0.25 | $2,466.75 | $246.68 | $2,220.08 |
| 11 | FU HING GARMENT FACTORY LTD. | 9,867 | $0.25 | $2,466.75 | $246.68 | $2,220.08 |
| | **TOTAL** | **150,363** | | **$54,015.25** | **$5,401.53** | **$48,613.73** |

| ID | COMPANY NAME | 8 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **150,363** | **$0.10** | | | |
| 1 | GRACE SUN CAMBODIA GARMENT LTD. | 852 | $0.60 | $511.20 | $51.12 | $460.08 |
| 2 | TERRATEX KNITTING & (INT'L) FACTORY LTD. | 30,000 | $0.53 | $15,900.00 | $1,590.00 | $14,310.00 |
| 3 | OCEANIC ( CAMBODIA ) GARMENT CO.,LTD. | 30,072 | $0.25 | $7,518.00 | $751.80 | $6,766.20 |
| 4 | NEW POINT WORLD TRADE (CAMBODIA) LTD. | 30,000 | $0.23 | $6,900.00 | $690.00 | $6,210.00 |
| 5 | SABRINA GARMENT MANUFACTURING CORP | 1,864 | $0.20 | $372.80 | $37.28 | $335.52 |
| 6 | POTAMON CAMBODIA LIMITED. | 30,000 | $0.18 | $5,400.00 | $540.00 | $4,860.00 |
| 7 | SUNTEX PTE LTD. | 27,575 | $0.15 | $4,136.25 | $413.63 | $3,722.63 |
| | **TOTAL** | **150,363** | | **$40,738.25** | **$4,073.83** | **$36,664.43** |

| ID | COMPANY NAME | 10 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **225,544** | **$0.05** | | | |
| 1 | UNITED ARTS GARMENT FACTORY LTD. | 5,700 | $0.09 | $513.00 | $51.30 | $461.70 |
| 2 | SUPREME GARMENT PTE LTD. | 6,000 | $0.08 | $480.00 | $48.00 | $432.00 |
| | **TOTAL** | **11,700** | | **$993.00** | **$99.30** | **$893.70** |

| ID | COMPANY NAME | 11 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **150,363** | **$0.05** | | | |
| 1 | TERRATEX KNITTING & (INT'L) FACTORY LTD. | 30,000 | $0.48 | $14,400.00 | $1,440.00 | $12,960.00 |
| 2 | NEW POINT WORLD TRADE (CAMBODIA) LTD. | 30,000 | $0.22 | $6,600.00 | $660.00 | $5,940.00 |
| 3 | POTAMON CAMBODIA LIMITED. | 30,000 | $0.17 | $5,100.00 | $510.00 | $4,590.00 |
| 4 | SUNTEX PTE LTD. | 30,072 | $0.15 | $4,510.80 | $451.08 | $4,059.72 |
| 5 | MIGHTI-SPECTRA KNITTING FACTORY CO.,LTD. | 20,000 | $0.10 | $2,000.00 | $200.00 | $1,800.00 |
| 6 | FORTUNE & WOOLEN KNITTING FACTORY LTD. | 10,291 | $0.05 | $514.55 | $51.46 | $463.10 |
| | **TOTAL** | **150,363** | | **$33,125.35** | **$3,312.54** | **$29,812.82** |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ...០៦៧.៧៤...កសក

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន

*********

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈ ០២ នស/ រកត/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខៈ នស/រកម/ ០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខៈ ១៧ អនក្រ.បកចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញគោលការណ៍អាស៊ាន ស្តីពីការវាយតំលៃនូវភាពគ្រោះថ្នាក់ អំពីសរីរាង្គបំរែបំរួល ផ្នែកហ្សែនទាក់ទង និងកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**ប្រការ១** : សំរេចបង្កើតក្រុមការងារ ដែលហៅថា : ក្រុមការងារគ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ដែលហៅជាភាសាអង់គ្លេសថា : Working Group on Agricultural Products Derived from Genetically Modified Organisms (GMOs) ។

**ប្រការ២:** ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន មានសមាសភាព ដូចខាងក្រោម:

| | |
|---|---|
| ១- ប្រធាន នាយកដ្ឋានកៀត្រសាស្ត្រ | ប្រធាន |
| ២- ប្រធាន នាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យាបាល | អនុប្រធាន |
| ៣- ប្រធាន នាយកដ្ឋានជលផល | សមាជិក |
| ៤- ប្រធាន នាយកដ្ឋាន រុក្ខាប្រមាញ់ | សមាជិក |
| ៥- ប្រធានវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ៦- ប្រធាននាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម | សមាជិក |
| ៧- ប្រធាននាយកដ្ឋាន នីតិកម្មកសិកម្ម | សមាជិក |
| ៨- ប្រធានការិយាល័យអាស៊ានកសិកម្ម | សមាជិក |

**ប្រការ៣ :** ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន GMOs មាន ភារកិច្ច ដូចខាងក្រោម:

ក- តាមដានគ្រប់គ្រងរាល់បណ្តាផលិតផលកសិកម្ម ក្នុងស្រុកទាំងអស់ចំពោះការផលិតចេញ ដែលមាន ពាក់ព័ន្ធជាមួយ GMOs ។

ខ- តាមដាននូវរាល់បណ្តាផលិតផលកសិកម្មទាំងអស់ ដែលនាំចូលមកពីបរទេស ហើយផលិតផល នោះជាផលិតផល ដែលបានមកពី GMOs ។

គ- ក្រុមការងារត្រូវធ្វើរបាយការណ៍ជាបន្ទាន់ ជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅពេលណាពិនិត្យឃើញថា មានផលិតផលកសិកម្ម ដែលបានមកពី GMOs ដែលប្រជាពលរដ្ឋ បាននឹងកំពុងប្រើប្រាស់ និងអាចមានផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ឃ- សំរបសំរួលការងារជាមួយបណ្តាប្រទេស ជាសមាជិកអាស៊ានទទួលបន្ទុក GMOs ដើម្បីប្រមូល ទិន្នន័យពត៌មាន ស្តីពីចរាចរទំនិញកសិកម្ម ដែលបានមកពី GMOs ផលប៉ះពាល់ដល់សុខភាព របស់ផលិតផល កសិកម្ម GMOs ។

ង- ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់សាធារណៈជន ប្រជាពលរដ្ឋ អំពីផលិតផលកសិកម្ម ដែលបានមកពី GMOs និងផលអាចប៉ះពាល់គ្រោះថ្នាក់ដល់សុខភាពរបស់ផលិតផលទាំងនោះ ។

**ប្រការ៤** : ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន GMOs ប្រើប្រាស់ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ជាលេខាធិការដ្ឋានរបស់ខ្លួន។

**ប្រការ៥** : រាល់លទ្ធផលការងារ ដែលទទួលបាន ប្រធានក្រុមការងារគ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសំរេច។

**ប្រការ៦**: អគ្គនាយក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ប្រធាននាយកដ្ឋានជលផល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ និងដូចមានចែងក្នុងប្រការ២ នៃក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ត្រូវអនុវត្តតាមសេចក្តីសំរេច នេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០១ ឆ្នាំ២០០២

ជ័ន្ទ-សារុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦

  "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សអ
MOSALVY

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ.........០២០.........សកបយ ភ្នំពេញ,ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការស្នើសុំយកកម្លាំងពលកម្មបរទេស មកធ្វើការយកប្រាក់ឈ្នួលនៅព្រះរាជាណាចក្រកម្ពុជា

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស-រកម-០៦៩៩-០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ-បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០២

## ស ំ រេ ច

ប្រការ ១: ប្រកាសនេះកំណត់នីតិវិធីនៃការស្នើសុំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួល នៅតាមសហគ្រាសគ្រឹះស្ថាននានា ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា ជនបរទេស ដែលធ្វើការយកប្រាក់ឈ្នួល ក្នុងប្រការ១នេះ មិនរាប់បញ្ចូលផងទេ នូវអ្នក

ការទូត បុគ្គលិកអង្គការអន្តរជាតិ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកជំនាញការ ឬទីប្រឹក្សារាជរដ្ឋាភិបាល ឬ ក្រសួងនានា និងអ្នកវិនិយោគទុន ដែលស្ថិតនៅក្រោមលក្ខន្តិកៈអ្នកការទូត ច្បាប់វិនិយោគទុន និងអង្គការមនុស្សធម៌ ដែលមានអនុស្សារណៈជាមួយស្ថាប័នរាជរដ្ឋាភិបាល ។

ជនបរទេសទាំងឡាយ ដែលបានកំណត់ក្នុងប្រការ១នេះ និងម្ចាស់សហគ្រាសគ្រឹះស្ថាន ដែលប្រើជនបរទេសទាំងនេះ ត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវតាម មាត្រា ២១ និង មាត្រា ២៦១ ដល់មាត្រា ២៦៥ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២: ជនបរទេសទាំងឡាយ ដូចដែលកំណត់ក្នុងប្រការ១ខាងលើ ត្រូវមានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញឱ្យដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទើបអាចធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ។

ចាប់ពីពេលនេះតទៅ សហគ្រាស គ្រឹះស្ថាននានា ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា១ នៃច្បាប់ស្តីពីការងារ នៅពេលត្រូវការនាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួល ត្រូវធ្វើសំណើជាលាយលក្ខអក្សរ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

សំណើនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី ចំនួន មុខជំនាញ បច្ចេកទេសនៃពលកម្មបរទេស និងប្រភពដែលត្រូវស្នើសុំយកជនបរទេស ព្រមទាំងលក្ខខណ្ឌការងារដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងពិនិត្យអនុញ្ញាតិផងដែរចំពោះប្រភពបេក្ខជនទាំងឡាយ ដែលត្រូវបានផ្តល់ជូនដោយនិយោជក ។

ប្រការ ៣: ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងផ្តល់អាជ្ញាបណ្ណ័ឱ្យក្រុមហ៊ុនឯកជនធ្វើជាទីភ្នាក់ងារនានា ទទួលបន្ទុកការងារនាំយកពលកម្មបរទេស ចូលមកធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមសំណើនីមួយៗ ។

ទីភ្នាក់ងារនានារបស់កម្ពុជា សហការជាមួយទីភ្នាក់ងារនានានៃប្រទេសដើមរបស់ជនបរទេស ដើម្បីធ្វើការពិនិត្យមើលអត្តសញ្ញាណ គុណវុឌ្ឍិ និងឯកសារផ្លូវច្បាប់របស់ជនបរទេសម្នាក់ៗ ។ ផ្អែកទៅតាមលទ្ធផលនៃការពិនិត្យនោះ ក្រសួងសំរេចអនុញ្ញាតិឱ្យនាំយកជនបរទេសចូលមកធ្វើការ នៅក្នុងសហគ្រាសគ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមករណីនីមួយៗ ហើយចាត់ឱ្យក្រុមហ៊ុនជាទីភ្នាក់ងារនានា រៀបចំឱ្យជនបរទេសចុះ កិច្ចសន្យាការងារជាមួយនឹងនិយោជក ស្របទៅតាមលក្ខខណ្ឌការងារ ដែលបានព្រមព្រៀងគ្នារួចហើយ ។

ចំពោះប្រភពបេក្ខជនទាំងឡាយដែលត្រូវបានផ្តល់ជូនដោយនិយោជក និយោជកអាចធ្វើការទាក់ទងជាមួយទីភ្នាក់ងារនៅប្រទេសរបស់សាមីជនបរទេសដោយផ្ទាល់ ដើម្បីកំណត់អំពីលក្ខខណ្ឌការងារ ។ ក្នុងករណីនេះ ទីភ្នាក់ងារនានានៃប្រទេសដើមរបស់សាមីជនបរទេស ត្រូវចុះកិច្ចសន្យានៃសេវាមុខរបរ ជាមួយទីភ្នាក់ងារនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលដែលសាមីជនបរទេស ត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

ទីភ្នាក់ងាររបស់ក្រសួង ទទួលខុសត្រូវចំពោះមុខក្រសួង ក្នុងការធានាឱ្យបានថា ជនបរទេសដែល

ត្រូវបាននាំចូលមកធ្វើការនៅតាមសហគ្រាសគ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា សុទ្ធតែៈ

-មានគុណវុឌ្ឍិគ្រប់គ្រាន់ ត្រូវទៅតាមសេចក្តីត្រូវការរបស់សហគ្រាសគ្រឹះស្ថាន

-មានឯកសារផ្លូវច្បាប់ត្រឹមត្រូវ ស្របទៅតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ

-ត្រូវបានទទួលការបណ្តុះបណ្តាលអំពីច្បាប់ ទំនៀមទម្លាប់ ប្រពៃណី ភាសាខ្មែរ ក្នុងរយៈពេលយ៉ាងតិច ៨សប្តាហ៍ មុនពេលចូលធ្វើការ ឬនៅពេលចាប់ផ្តើមធ្វើការដំបូង។

-ត្រូវបានធានាសិទ្ធិស្របច្បាប់ នៅពេលដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤ ៈ ចំពោះជនបរទេស ដែលមកពីប្រទេសផ្សេងៗ នៅមិនទាន់មានក្រុមហ៊ុនឯកជនជាទីភ្នាក់ងារទទួលបន្ទុកនៅឡើយ ក្រសួងនឹងពិនិត្យ និងសំរេចលើសំណើសុំនាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួលនៅព្រះរាជាណាចក្រកម្ពុជា របស់សហគ្រាសគ្រឹះស្ថាន ដោយផ្ទាល់។ ក្នុងករណីនេះ សហគ្រាសគ្រឹះស្ថានត្រូវចុះកិច្ចសន្យាជាមួយសាមីជនបរទេស និងត្រូវធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេសភ្លាម នៅពេលដែលជនបរទេសចូលមក ដល់ព្រះរាជាណាចក្រកម្ពុជា។ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក (ចលនាបគ្គលិកចូល) ក៏ត្រូវធ្វើឱ្យបានស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ប្រការ ៥ៈ កិច្ចសន្យាការងាររបស់ជនបរទេស ក្នុងមួយលើកៗ មានរយៈពេលមិនលើសពី ២ឆ្នាំ ឡើយ។ កិច្ចសន្យាការងារអាចធ្វើជាភាសាបរទេសបាន តែត្រូវមានភាសាខ្មែររួមជាមួយផងដែរ។ កិច្ចសន្យាការងារត្រូវកំណត់ឱ្យបានច្បាស់អំពីលក្ខខណ្ឌការងារសំខាន់ៗ និងឱ្យបានស្របតាមច្បាប់ស្តីពីការងារ ។ បើចង់បន្តធ្វើការងារនៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសត្រូវមានការអនុញ្ញាតិឱ្យធ្វើការងារនៅកម្ពុជា ជាថ្មីម្តងទៀត។

ប្រការ ៦ ៈ ពេលចូលមកធ្វើការយកប្រាក់ឈ្នួលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសម្នាក់ៗ ត្រូវៈ

ក. ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រឹមត្រូវតាមច្បាប់

ខ. មានលិខិតឆ្លងដែនត្រឹមត្រូវ

គ. មានប័ណ្ណស្នាក់នៅត្រឹមត្រូវ

ឃ. មានសញ្ញាប័ត្រ ឬឯកសារណាមួយបញ្ជាក់ថា មានបច្ចេកទេសមុខជំនាញវិជ្ជាជីវៈសមស្រប ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ច របស់ប្រទេសសាមីជនបរទេស ឬប្រទេសណាមួយ

ង. មានវិញ្ញាបនប័ត្រ ឬលិខិតណាមួយបញ្ជាក់ថា សាមីជនបរទេស មានកាយសម្បទាសមស្របទៅនឹងមុខរបរដែលត្រូវធ្វើ និងមិនមានជំងឺឆ្លងណាមួយឡើយ ដែលត្រូវបានចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា ឬ ស្ថាប័នមានសមត្ថកិច្ច នៃប្រទេសដើមរបស់សាមីជនបរទេស ឬ ប្រទេសដែលសាមីជនបរទេសស្នាក់នៅ។

ប្រការ ៧ៈ ចាប់ពីពេលនេះតទៅ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មិនអនុញ្ញាតិឱ្យសហគ្រាសគ្រឹះស្ថាននានា នាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតិពីក្រសួងជាមុនឡើយ។

ចំពោះជនបរទេសដែលបានចូលមកធ្វើការរួចហើយ មុនពេលចេញប្រកាសនេះ តែនៅមិនទាន់មានប័ណ្ណការងារ និងសៀវភៅការងារ ត្រូវរៀបចំបែបបទស្នើសុំបណ្ណ័ការងារ និងសៀវភៅការងារឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ ២០០២ ។

ចំពោះសហគ្រាសគ្រឹះស្ថាន ដែលបានទទួលយកជនបរទេសឱ្យចូលមកធ្វើការរួចហើយ មុនពេលចេញប្រកាសនេះ តែនៅមិនទាន់បានធ្វើសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ត្រូវរៀបចំបែបបទធ្វើសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ឱ្យបានមុនថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ។ បើនៅមិនទាន់មានកិច្ចសន្យាការងារទេ និយោជក និងសាមីជនបរទេស ក៏ត្រូវចុះកិច្ចសន្យាការងារនៅពេលជាមួយគ្នានេះដែរ ។

ប្រការ៨: ម្ចាស់សហគ្រាសគ្រឹះស្ថាន ត្រូវធ្វើសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ជាលាយលក្ខអក្សរស្ដីពីការទទួលជនបរទេសឱ្យចូលធ្វើការ នៅពេលចុះកិច្ចសន្យាការងារ ឬបញ្ឈប់ជនបរទេសពីការងារ នៅពេលបញ្ចប់កិច្ចសន្យាការងារ ឬនៅពេលផ្ដាច់កិច្ចសន្យាការងារ ។ សេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះ ត្រូវបញ្ជូនទៅក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចុះបញ្ជិកា ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលឱ្យធ្វើការ ឬបញ្ឈប់ពីការងារ ។ ចំពោះអ្នកនៅរាជធានីភ្នំពេញ សេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ត្រូវបញ្ជូនទៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ។ ចំពោះអ្នកនៅខេត្តក្រុង សេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះ ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៃខេត្តក្រុងនីមួយៗ ។

ប្រការ៩ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន** :

-ក្រសួងព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្តក្រុង

" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

-សមាគមនិយោជក

-សហព័ន្ធសហជីព

" ដើម្បីជ្រាប "

-គ្រប់បណ្ដាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**